ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង

ខេត្តបន្ទាយមានជ័យ

សំណុំរឿងរដ្ឋប្បវេណីលេខៈ៣៤១

ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៨

សាលក្រមរដ្ឋប្បវេណីលេខៈ ៤៥ (ញ)/៩៩៣

ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩

# សាលក្រម

## ក្នុងនាមប្រជាពលរដ្ឋខ្មែរ

## សាលាដំបូងខេត្តបន្ទាយមានជ័យ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃព្រហស្បតិ៍ ៨កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ២៥៦៣ ត្រូវនឹងថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ ប្រកាសសាលក្រមនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ ដោយមានសមាសភាពជំនុំជម្រះដូចតទៅ

### ចៅក្រមជំនុំជម្រះ

លោក **ឃ្លោក ពិសិដ្ឋ** ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ

### ក្រឡាបញ្ជីសវនាការ

លោក **ហ៊ុន ចិត្រា** ក្រឡាបញ្ជីនៃសាលាដំបូងខេត្តបន្ទាយមានជ័យ

**ដើមចោទ**

ឈ្មោះ **ជ** ភេទស្រី កើតឆ្នាំ ១៩៦៨ មុខរបរ ធ្វើស្រែ មានទីលំនៅសព្វថ្ងៃ ខេត្តបន្ទាយមានជ័យ **ឪពុក ឆ** (ស្លាប់) **ម្ដាយ ជ** (ស្លាប់) **ប្ដី ឍ** មានកូន០៥នាក់។

**ចុងចម្លើយ**

ឈ្មោះ **ច** ភេទប្រុស អាយុ៥៥ឆ្នាំ មុខរបរ ធ្វើស្រែ មានទីលំនៅសព្វថ្ងៃ ខេត្តបន្ទាយមានជ័យ **ឪពុក ប** (ស្លាប់) **ម្ដាយ ច** (ស្លាប់) **ប្រពន្ធ ថ** មានកូន០៥នាក់។

### អង្គហេតុ និង ចំណុចវិវាទ

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ**

១-ប្រាក់ដើមចំនួន៥៧០០០(ហាសិបប្រាំពីរពាន់)បាត។

២-ការប្រាក់គិត១០% ដោយចាប់គិតតាំងពីថ្ងៃគាត់ឈប់បង់រហូតដល់សព្វថ្ងៃនេះ

៣-ទាមទារជំងឺចិត្តចំនួន៥,០០០,០០០ (ប្រាំលាន)រៀល។

**ខ. ដំណើររឿងក្ដី និង ចំណុចវិវាទ**

ខ.១. ការសង្ខេបអំពីរឿងក្ដី

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្ដីជាក់ស្ដែង ហើយមិនមែនជាសាលក្រមគំរូទេ

នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៦ ចុងចម្លើយចងការប្រាក់ដើមចោទចំនួន៥៧០០០(ប្រាំម៉ឺនប្រាំពីរពាន់)បាតដោយសន្យាគិតការប្រាក់ក្នុង១ខែ ៥៧០០(ប្រាំពាន់ប្រាំពីររយ)បាត ដោយចុងចម្លើយប្រាប់ថាគាត់យកតែកន្លះខែទេ ហើយតាំងពីគាត់ចាប់ផ្តើមខ្ចីប្រាក់ដើមចោទមកចុងចម្លើយបានបង់ការប្រាក់ឱ្យដើមចោទបានចំនួន៤(បួន)ខែតែប៉ុណ្ណោះ ហើយរហូតមកដល់សព្វថ្ងៃចុងចម្លើយមិនបានបង់ទៀតទេ ដើមចោទបានរៀបរាប់ថាប្រាក់ដែលខ្លួនយកមកចងការឱ្យចុងចម្លើយនោះ គឺដើមចោទបានទៅចងការបន្តពីគេមកទេគឺមិនមានប្រាក់ខ្លួនឯងទេ តែឥឡូវម្ចាស់ប្រាក់គេបានទាមទារប្រាក់ពីដើមចោទរហូត។

**ខ.២. អង្គហេតុដែលគ្មានវិវាទ**

- ប្រាក់ដើមចំនួន ៥៧០០០( ប្រាំម៉ឺនប្រាំពីរពាន់ )បាត។

**ខ.៣. ចំណុចវិវាទ**

-ដើមចោទទាមទាមការប្រាក់១០% ក្នុង១ខែ លើដើមចំនួន ៥៧០០០( ប្រាំម៉ឺនប្រាំពីរពាន់ )បាត។

-ចុងចម្លើយមិនទទួលស្គាល់ការប្រាក់១០% ក្នុង១ខែទេ ។

**ខ.៤. ការអះអាងរបស់គាត់ស្តីពីចំណុចវិវាទ**

**ខ.៤.១.ស្តីពីចំណុចវិវាទទី១** (តើចុងចម្លើយយល់ព្រមសងថ្លៃខាតបង់ពេលវេលា ដូចនៅក្នុងកម្មវត្ថុដែលដើមចោទប្តឹងទាមទាចំនួន ៥.០០០.០០០(ប្រាំលាន)រៀល ដែរឬទេ ) ។

**ខ.៤.២.ស្តីពីចំណុចវិវាទទី២** (តើចុងចម្លើយយល់ព្រមសងការប្រាក់១០%ក្នុង១ខែ លើប្រាក់ដើម៥៧០០០(ប្រាំម៉ឺនប្រាំពីរពាន់)បាត ឲ្យទៅដើមចោទទាមទារ ដែរឬទេ )។

ការអះអាងរបស់ដើមចោទ

ខ្លួនសូមប្រាប់លោកចៅក្រមថា ចុងចម្លើយចងការប្រាក់ខ្លួនចំនួន៥៧០០០(ប្រាំម៉ឺនប្រាំពីរពាន់) បាត នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៦ តែគ្រាន់តែសរសេរក្នុងសៀវភៅតែប៉ុណ្ណោះដោយសន្យាគិតការប្រាក់ក្នុង១ខែ ៥៧០០(ប្រាំពាន់ប្រាំពីររយ)បាត ដោយចុងចម្លើយប្រាប់ថាគាត់យកតែកន្លះខែទេ ហើយរហូតមកដល់ពេលនេះគាត់បានបង់ការប្រាក់បានចំនួន៤ខែតែប៉ុណ្ណោះ ហើយរហូតមកដល់សព្វថ្ងៃគាត់មិនបានបង់បន្តទៀតទេ រហូតដល់ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៧ គាត់ក៏បានទៅធ្វើកិច្ចសន្យានៅកន្លែងប៉ុលីសម្តងទៀត តែគាត់នៅតែមិនព្រមសងដដែរ នាងខ្ញុំសុំជម្រាបចៅក្រមថា ប្រាក់ដែលនាងខ្ញុំយកមកចងការឱ្យចុងចម្លើយនោះគឺខ្លួនបានទៅចងបន្តពីគេមកទេគឺមិនមានប្រាក់ខ្លួនឯងទេ តែឥឡូវម្ចាស់ប្រាក់គេបានទាមទារប្រាក់ពីខ្លួនរហូត ចំពោះឯកសារមាន លិខិតទទួលស្គាល់ជំពាក់ប្រាក់ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៧ ។ ហេតុដូច្នេះខ្លួនទាមទារឱ្យគាត់សងប្រាក់ដូចខាងក្រោមៈ

១-ដើមចំនួន៥៧០០០(ប្រាំម៉ឺនប្រាំពីរពាន់)បាត។

២-ការប្រាក់គិត១០% ដោយចាប់គិតតាំងពីថ្ងៃគាត់ឈប់បង់រហូតដល់សព្វថ្ងៃនេះ ។

៣-ទាមទារជំងឺចិត្តចំនួន៥.០០០.០០០ (ប្រាំលាន)រៀល។

ការអះអាងរបស់ចុងចម្លើយ

ខ្លួនមិនទទួលស្គាល់ប្រាក់ការប្រាក់១០%ទេ ហើយចំណែកការទាមទារជំងឺចិត្តចំនួន៥.០០០.០០០ (ប្រាំលាន)រៀលក៏ខ្លួនអត់ទទួលស្គាល់ដែរ តែចំពោះប្រាក់ដើមចំនួន ៥៧០០០(ប្រាំម៉ឺនប្រាំពីរពាន់)បាត ខ្លួនទទួលស្គាល់ថាបានខ្ចីគាត់ពិតប្រាកដមែន តែពេលនេះខ្លួនសុំសងប្រាក់ដើមឱ្យដើមបណ្តឹងក្នុងមួយខែចំនួន ៣០០០(បីពាន់)បាត លើសពីនេះខ្លួនមិនមានលទ្ធភាពទេ។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

## សំអាងហេតុ

### ក. ស្តីពីចំណុចទាមទារទី១

ដើមបណ្តឹងបានទាមទារឱ្យចុងចម្លើយសងថ្លៃខាតបង់ពេលវេលាចំនួន ៥,០០០,០០០ (ប្រាំលាន) រៀល ដូច្នេះតុលាការទទួលស្គាល់ការប្តឹងសុំរបស់ដើមចោទ ។

### ខ. ស្តីពីចំណុចទាមទារទី២

ដើមបណ្តឹងបានទាមទារឱ្យចុងចម្លើយសងការប្រាក់១០%ក្នុង១ខែ លើប្រាក់ដើម៥៧០០០(ប្រាំម៉ឺនប្រាំពីរពាន់)បាត ។ ដូច្នេះតុលាការកំណត់ឲ្យចុងចម្លើយបង់ការប្រាក់១៨%ក្នុង១ឆ្នាំតាមច្បាប់កំណត់

### គ. ការវិនិច្ឆ័យអំពីការទាមទារ

យោងតាមការកិច្ចសន្យាយល់ព្រមប្រគល់ប្រាក់ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧ រវាងដើមចោទ និងចុងចម្លើយ បានបញ្ជាក់ឲ្យឃើញថា ចុងចម្លើយពិតជាបានជំពាក់ប្រាក់ដើមចោទចំនួន ៥.៧០០០ (ប្រាំម៉ឺនប្រាំពីរពាន់)បាត ។ការលើកឡើងរបស់ដើមចោទនេះ ចុងចម្លើយបានឯកភាពថាពិតជាបានជំពាក់ប្រាក់ដើមចោទដូចដែលចំនួនដើមចោទបានទាមទារមែន អាចឱ្យតុលាការលើកយកពិចារណា និងសម្រេចបាន ។

ដើមបណ្តឹងបានទាមទារឱ្យចុងម្លើយសងការខាតបង់ពេលវេលាចំនួន ៥,០០០,០០០ (ប្រាំលាន) រៀល និងការប្រាក់១០%ក្នុង១ខែ ។ ដូច្នេះតុលាការនឹងធ្វើការសម្រេចតាមតថភាពជាក់ស្តែង ដោយអនុលោមតាមមាត្រា ៤០០ នៃក្រមរដ្ឋប្បវេណី ។

យោងតាមបញ្ញត្តិមាត្រា ៥៧៨ (និយមន័យនៃការបង្កើតកិច្ចសន្យា)មាត្រា៥៧៩ (ការបង្កើតកិច្ចសន្យា មាត្រា ៥៨៣ (សិទ្ធិលើបំណុលដែលជាការប្រាក់)មាត្រា ៥៨៤ (អត្រាការប្រាក់ដែលបានកំណត់ដោយច្បាប់ និងអត្រាការប្រាក់ក្នុងកិច្ចសន្យា)មាត្រា៥៨៥ (ការកម្រិតការប្រាក់) នៃក្រមរដ្ឋប្បវេណី និងប្រកាសលេខ១២៨ កយ.ប្រក/១១(ស្តីអំអត្រាការប្រាក់ដែលត្រូវបានកម្រិត) ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ មិនឲ្យលើសពី១៨% (ដប់ប្រាំបី)ភាគរយក្នុងមួយឆ្នាំ ដើមចោទសុំឲ្យចុងចម្លើយទូទាត់សងការប្រាក់ចំនួន១០% (ដប់ភាគរយ) នៃប្រាក់ដើមក្នុងមួយខែមកឲ្យដើមចោទ គិតចាប់ពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧ រហូតដល់ពេលចុងចម្លើយទូទាត់សងប្រាក់គ្រប់ចំនួននោះតុលាការពិនិត្យឃើញថាលើសពីច្បាប់កំណត់ គម្បីតុលាការសម្រេចការប្រាក់លើប្រាក់ដើម១៨% ក្នុងមួយឆ្នាំតាមកំណត់ច្បាប់។

### ឃ. ស្តីពីបន្ទុកនៃប្រាក់ប្រដាប់ក្តី

នៅក្នុងរឿងនេះ ដើមចោទប្តឹងសុំឲ្យចុងចម្លើយជាអ្នកទទួលបន្ទុក ចំពោះប្រាក់ប្រដាប់ក្តី និងប្រាក់ពន្ធនាៗ គប្បីតុលាការសម្រេចតាមមាត្រា ៦៤ កថាខណ្ឌ ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ភាគីចាញ់ក្តី ។ ក្នុងករណីដែលបានចាញ់ក្តីតែមួយភាគទេ តុលាការត្រូវសម្រេចនូវបន្ទុកដែលភាគីម្នាក់ៗត្រូវទទួលដោយធន្ទានុសិទ្ធិរបស់ខ្លួន ។

### ង. ស្តីពីការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន

ការទាមទាររបស់ដើមចោទ គឺជាការទាមទារប្រាក់ ហើយតុលាការយល់ឃើញថា មានភាពចាំបាច់ ដូច្នេះប្រកាសថា ចំណុចទី១ នៃកម្មវត្ថុនៃបណ្តឹងរបស់ដើមចោទអាចអនុវត្តជាបណ្តោះអាសន្នបាន ។

សរុបជារួម តុលាការនឹងសម្រេចអំពីរឿងក្តីស្តីពីការទាមទារឲ្យសងប្រាក់កម្ចីនៃរឿងក្តីនេះដូចខាងក្រោម:

## សេចក្តីសម្រេចបញ្ចប់

I-ទទួលស្គាល់បណ្តឹងរបស់ដើមចោទទុកជាបានការស្របតាមច្បាប់ ។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

II-បង្គាប់ឱ្យចុងចម្លើយឈ្មោះ ត ភេទប្រុស អាយុ ៥៥ឆ្នាំ សងប្រាក់ដើមចំនួន៥,៧០០០ (ប្រាំម៉ឺនប្រាំពីរពាន់)បាត ទៅឱ្យដើមចោទឈ្មោះ ផ គិតពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៦ រហូតដល់ថ្ងៃសងប្រាក់អស់ ។

III-បង្គាប់ឱ្យចុងចម្លើយឈ្មោះ ត ភេទប្រុស អាយុ ៥៥ឆ្នាំ សងការប្រាក់១៨%ក្នុង១ឆ្នាំលើប្រាក់ដើមចំនួន៥,៧០០០ (ប្រាំម៉ឺនប្រាំពីរពាន់)បាត គឺស្មើចំនួន៨៥៥ (ប្រាំបីរយហាសិបប្រាំ)បាតក្នុង១ខែគិតពីថ្ងៃមិនទាន់បង់ប្រាក់រហូតដល់ថ្ងៃបង់គ្រប់ចំនួន យោងតាមប្រកាសលេខ១២៨ កយ. ប្រក/១១ (ស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត) ចុះថ្ងៃទី២១ខែធ្នូ ឆ្នាំ២០១១ មិនឲ្យលើស១៨% ។

IV-បង្គាប់ឲ្យចុងចម្លើយសងសំណងការយឺតយ៉ាវចំនួន៤.០០០.០០០(បួនលាន)រៀល ទៅឱ្យដើមចោទឈ្មោះ ត ការទាមទារលើសពីនេះច្រានចោល ។ ។

V-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះត្រូវបានប្រកាសនៅសវនាការជាសាធារណៈនាថ្ងៃព្រហស្បតិ៍ ៨កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ២៥៦៣ ត្រូវនឹងថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ ប្រកាសសាលក្រមនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ ។ ចំពោះមុខដើមចោទ និងកំបាំងមុខចុងចម្លើយ ។ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងក្នុងរយៈពេល ០១(មួយ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រមនេះ ។

ទុកសិទ្ធិប្តឹងជំទាស់តាមកំណត់ច្បាប់ ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣

មន្ទីរមានជ័យ ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩

**ចៅក្រម**

ឈុក ពិសិដ្ឋ